


Comcast RISE ប្ដេជ្ញាគាំទ្រការអភិវឌ្ឍអាជីវកម្មខ្នាតតូចទាំងអស់ឲ្យរីកចម្រើនតាមរយៈការជំរុញឲ្យសម្រេចបាននូវគោលបំណងនៃភាពចម្រុះ សមធម៌ និងបរិយាប័ន្ន ក៏ដូចជាការវិនិយោគសហគមន៍។ កម្មវិធីនេះត្រូវបានបង្កើតឡើងដើម្បីជួយអាជីវកម្ម និងសហគមន៍របស់ពួកគេឱ្យរីកចម្រើនដោយផ្តោតលើកំណើនសេដ្ឋកិច្ច។ នៅឆ្នាំនេះ គម្រោង Comcast RISE នឹងប្រគល់រង្វាន់ដល់អ្នកទទួលរង្វាន់ចំនួន 500 នាក់នៅក្នុងទីក្រុងចំនួន 5 ជាមួយនឹងកញ្ចប់ជំនួយដែលរួមមានសេវាប្រឹក្សាអាជីវកម្ម ធនធានអប់រំ ជំនួយជាទឹកប្រាក់ ការផលិតដោយច្នៃប្រឌិត ប្រព័ន្ធផ្សព្វផ្សាយ និងការបង្កើតបច្ចេកវិទ្យា។

Comcast RISE មានន័យថាការតំណាងឱ្យ( Representation) ការវិនិយោគ (Investment) ភាពរឹងមាំ (Strength) និងការផ្ដល់សិទ្ធិអំណាច (Empowerment)។ Comcast RISE ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2020 ដើម្បី ជួយអាជីវកម្មខ្នាតតូចដែលរងគ្រោះដោយវិបត្តិ Covid-19 ងើបឡើងវិញ និងរីកចម្រើន។ ក្នុងអំឡុងពេលកម្មវិធីពីរឆ្នាំដំបូងរបស់ខ្លួន អាជីវកម្មខ្នាតតូចចំនួន 13,000 កន្លែងត្រូវបានផ្តល់រង្វាន់ជាង $110 លានដុល្លារជាជំនួយទឹកប្រាក់ ជំនួយទីផ្សារ និងជំនួយបច្ចេកវិទ្យា។ ដោយដកស្រង់បទពិសោធន៍កន្លងមករបស់យើង យើងមានសេចក្ដីសោមនស្សរីករាយសូមនាំយកកម្មវិធី Comcast RISE ត្រឡប់មកវិញក្នុងឆ្នាំ 2023 នេះ។ នៅពេលដែលអាជីវកម្មខ្នាតតូចផ្លាស់ប្តូរពីការស្ទុះងើបឡើងវិញពីវិបត្តិជំងឺកូវីដទៅផ្តោតយកចិត្តទុកដាក់លើការពង្រីក និងកំណើន Comcast នឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន និងជួយដល់អាជីវកម្មខ្នាតតូចកាន់តែច្រើន ស្របពេលបន្តផ្តោតលើភាពចម្រុះ បរិយាប័ន្ន និងការវិនិយោគសហគមន៍។

Comcast RISE គឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីជាច្រើនដែល Comcast បានគ្រប់គ្រងជាផ្នែកនៃគម្រោង Project UP ដែលមានបំណងកាត់បន្ថយគម្លាតឌីជីថល និងសម្រេចបានសមធម៌ឌីជីថល។

## ព័ត៌មានលម្អិតអំពីកម្មវិធី

រង្វាន់សរុប 500 រង្វាន់នឹងចែកចាយដូចខាងក្រោម៖

•អាជីវកម្មខ្នាតតូច 100 កន្លែងក្នុងទីក្រុងនីមួយៗ

•អាជីវកម្មនីមួយៗនឹងទទួលបាន៖

- ○ ជំនួយជាទឹកប្រាក់ $5,000 ៖
- ○ ការផលិតដោយច្នៃប្រឌិត ប្រព័ន្ធផ្សព្វផ្សាយ និងការបង្កើតបច្ចេកវិទ្យា
- ○ ឧបាស្រ័យអប់រំ
- ○ សេវាកម្មប្រឹក្សាអាជីវកម្ម

•រយៈពេលដាក់ពាក្យសុំគឺ ថ្ងៃទី 1-30 ខែមិថុនា ឆ្នាំ 2023

•ជំនួយនឹងត្រូវបានប្រកាសនៅចុងខែសីហា និងប្រគល់រង្វាន់ក្នុងខែកញ្ញា ឆ្នាំ 2023

• ពាក្យសុំនឹងមានលើអនឡាញ តាមគេហទំព័រ www.comcastrise.com។

## លក្ខខណ្ឌក្នុងការចូលរួមកម្មវិធីនេះ

ដើម្បីមានសិទ្ធិចូលរួមកម្មវិធីនេះ អាជីវកម្មត្រូវតែ៖

•បានបង្កើតឡើង រយៈពេល 3 ឆ្នាំ ឬច្រើនជាងនេះ

• មាន បុគ្គលិកពេញម៉ោង ឬក្រៅម៉ោងចំនួន 100 នាក់ ឬតិចជាងនេះ

• ជាម្ចាស់កម្មសិទ្ធិ និងដំណើរការដោយឯករាជ្យ

•ស្ថិតនៅក្នុងទីតាំងភូមិសាស្ត្រដូចខាងក្រោម៖

**Baltimore** (ទីក្រុង Baltimore)
**Detroit** (ខោនធី Macomb ខោនធី Oakland ខោនធី Wayne ខោនធី Washtenaw)
**Memphis** (ខោនធី Shelby)
**Philadelphia** (ខោនធី Philadelphia)
**Portland** (ខោនធី Multnomah)

•សម្រាប់បញ្ជីពេញលេញនៃព័ត៌មានលម្អិតអំពីលក្ខខណ្ឌចូលរួមកម្មវិធីនេះ ចូលមើលគេហទំព័រ www.comcastrise.com

**ឥឡូវនេះ ដល់ពេលហើយដែលត្រូវក្រោកឡើង**
ដាក់ពាក្យនៅថ្ងៃនេះ។
**ComcastRISE.com**

COMCAST RISE

© 2021 Comcast. All rights reserved. Comcast confidential and proprietary information.